NATIONAL AIDS AUTHORITY

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ ៖ ......០០៥៤/......អ.ជ.ប.ជ.អ
/១៧ ៣៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផលិតសម្ភារសម្រាប់ផ្សព្វផ្សាយព័ត៌មានអំពីជំងឺអេដស៍ ប្រចាំឆ្នាំ២០១៧

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា៖ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ការផលិតសម្ភារផ្សព្វផ្សាយព័ត៌មានអំពីជំងឺអេដស៍ប្រចាំឆ្នាំ២០១៧ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានអាសយដ្ឋាន លេខ១៦ ផ្លូវលេខ២៧១កែង១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៥ ខែ ឧសភាឆ្នាំ ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ០២៣- ៨៨២០៧១ ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង៩.៣០នាទី ព្រឹក ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង ៩.៣០នាទីព្រឹក ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ...០៤..... ខែ ឧសភាឆ្នាំ ២០១៧

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អៀង - មូលី**

**ចម្លងជូន ៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ២៧១កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh